ខេត្ត-ក្រុង ព្រមទាំងនាយកដ្ឋានពាក់ព័ន្ធត្រូវទទួលបន្ទុក អនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**គាត ឈន់**

* * *

## ២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**ប្រកាសលេខ ១០២ ឧរ ប្រក**

**អនុញ្ញាតឱ្យក្រុមហ៊ុន SERIKA Co Ltd**

**ធ្វើអាជីវកម្មខ្សាច់ ស នៅតំបន់តាម៉ាន់**

**ពាមរាំង ក្នុងខេត្ត កោះកុង**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញលិខិតអនុញ្ញាតអោយធ្វើអាជីវកម្មខ្សាច់ស ក្នុងខេត្តកោះកុង របស់គណៈកម្មាធិការ វិនិយោគកម្ពុជា លេខ ១០២៣/៩៥ គវិក ចុះថ្ងៃទី ២៧-១១-១៩៩៥
- បានឃើញកិច្ចព្រមព្រៀងវិនិយោគទុនធ្វើអាជីវកម្មខ្សាច់សនៅតំបន់ តាម៉ាន់ ពាមរាំងក្នុងខេត្ត កោះកុង ចុះថ្ងៃ ០៨ ខែធ្នូ ឆ្នាំ ១៩៩៥

– បានឃើញពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មខ្សាច់សរបស់ក្រុមហ៊ុន SERIKA CO Ltd លេខ ០៩/៩៥ សរក ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**សម្រេច**

**ប្រការ ១ :** អនុញ្ញាតអោយក្រុមហ៊ុន SERIKA CO Ltd មានអាសយដ្ឋានផ្ទះលេខ ១០៦ ផ្លូវលេខ ៣១០ សង្កាត់បឹងកេងកងទី ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ធ្វើ អាជីវកម្មខ្សាច់ស នៅតំបន់ **តាម៉ាន់ ពាមរាំង** ក្នុងខេត្តកោះកុង លើផ្ទៃដី ៣០ គីឡូម៉ែត្រក្រឡា មានកូអរដោនេដូចតទៅ ÷

| ចំណុច | ខ្សែរយៈបណ្តោយ | ខ្សែរយៈទទឹង |
|---|---|---|
| A | 103$^0$ 00'35"E | 11$^0$ 37'11" N |
| B | 103$^0$ 03'50"E | 11$^0$ 37'11" N |
| C | 103$^0$ 03'50"E | 11$^0$ 34'22" N |
| D | 103$^0$ 00'35"E | 11$^0$ 34'22" N |

**ប្រការ ២ :** ក្រុមហ៊ុន SERIKA CO Ltd ត្រូវដំណើរការងារអាជីវកម្មខ្សាច់ស លើផ្ទៃដីដែលបានកំណត់នេះ ដោយធានាអនុវត្តតាមបច្ចេកទេសអាជីវកម្ម ។

**ប្រការ ៣ :** ប្រកាសនេះមានតំលៃក្នុងរយៈពេល ២(ពីរ) ឆ្នាំ ។ ផុតកំណត់នេះក្រុមហ៊ុនត្រូវដាក់ពាក្យសុំអនុញ្ញាតធ្វើអាជីវកម្មខ្សាច់សបន្ត ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនិងត្រូវដកហូតវិញដោយគ្មានលក្ខខណ្ឌ ។

**ប្រការ ៤ :** ប្រធាននាយកដ្ឋានភូគព្ភសាស្ត្រ រ៉ែ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធានមន្ទីរនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកោះកុងប្រធានក្រុមហ៊ុនត្រូវ ទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀង ៗ ខ្លួន ។

**ប្រការ ៥ :** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។